ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៥៣/២០ - មេរីឌាន អ៊ិនជាសស្ត្រី ហ្គាមេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ហែម ហួណារិទ្ធ**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **រុន សារ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន មេរីឌាន អ៊ិនជាសស្ត្រី ហ្គាមេន (ខេមបូឌា) លីមីតធីត**
អាសយដ្ឋាន ៖ ភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៨៤២ ៧៣៧ / ០៩៧ ២៩ ២៩ ៩២២ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក CHEN WENKE នាយកក្រុមហ៊ុន
២- លោក ជិន ជារិទ្ធ មន្ត្រីផ្នែកច្បាប់

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន មេរីឌាន អ៊ិនជាសស្ត្រី ហ្គាមេន (ខេមបូឌា) លីមីតធីត**
អាសយដ្ឋាន ៖ ភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៥ ៩៩២ ៤២៦ / ០៩២ ៦០០ ៩៥៧ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក អ៊ិន មករា ប្រធានសហព័ន្ធសហជីពពន្លឺកម្មករកម្ពុជា
២- លោក នៅ ប៊ុនជឿន ប្រធានសហជីពមូលដ្ឋាន
៣- លោក ឈុន បូរី លេខាសហជីពមូលដ្ឋាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនជួយសម្រួលដល់អគារនីមួយៗ ឱ្យមានភាពត្រជាក់ដល់បងប្អូនកម្មករឡើងវិញផង។ ក្រុមហ៊ុនមិនឯកភាព។

២- ស្នើសុំឱ្យក្រុមហ៊ុនកុំរើសអើងសហជីព។ មិនសះជានឹងគ្នា។

៣- ស្នើសុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យតំណាងសហជីព ចេញចូលដូចសហជីពដទៃទៀតបាន ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗឱ្យនៅដដែល។ មិនសះជានឹងគ្នា។

៤- ស្នើសុំឱ្យក្រុមហ៊ុនជួយទូទាត់ប្រាក់រង្វាន់ ឬលុយទៀងទាត់ ជូនបងប្អូនកម្មករឡើងវិញ។ មិនសះជានឹងគ្នា។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន មេរីខាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត លេខ ៥៩៨/២០ ក.ប/កណ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ១៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០២ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលលិខិតស្នើសុំជួយអន្តរាគមន៍ឱ្យនិយោជកដោះស្រាយវិវាទការងាររួម ដែលពាក់ព័ន្ធនឹងការទាមទាររបស់កម្មករនិយោជិតចំនួន ៤ចំណុច។ បន្ទាប់ពីទទួលបានលិខិតស្នើសុំនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានអញ្ជើញភាគីពាក់ព័ន្ធទាំងអស់មកចូលរួមសម្របសម្រួល និងធ្វើការផ្សះផ្សាចំណុចវិវាទនេះ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចវិវាទដែលមិនសះជាចំនួន ៤ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ តាម

THE ARBITRATION COUNCIL

របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្រ្ទី ហ្គាមេន (ខេមបូឌា) លេខ ៥៩៨/២០ ក.ប/កណ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៤ចំណុចនេះ នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុម-ប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៤ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយក្នុងនោះភាគីទាំងពីរបានព្រមព្រៀងគ្នាចំនួន ៣ចំណុច គឺចំណុចវិវាទទី១, ទី២, និងទី៣។ ភាគីកម្មករនិយោជិតសម្រេចបញ្ចូលចំណុចវិវាទទី ២ និងទី៣ ជាចំណុចវិវាទតែមួយ ហើយភាគីទាំងពីរស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសរសេរកិច្ចព្រមព្រៀងខាងលើនៅក្នុងសេចក្តីបង្គាប់នេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទមិនសះជាដែលនៅសល់ចំនួន ១ចំណុច គឺចំណុចវិវាទទី៤។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- សារណាសង្ខេបនៃវិវាទការងាររបស់ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្រ្ទី ហ្គាមេន (ខេមបូឌា) លីមីតធីត ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្រ្ទី ហ្គាមេន (ខេមបូឌា) លីមីតធីត លេខ MOC-៧១២៩៧០២៦ ពណ.ចបព ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១២។

៣- លក្ខន្តិកៈក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្រ្ទី ហ្គាមេន (ខេមបូឌា) លីមីតធីត បានតម្កល់ទុកលេខ ០៧០៥/២០១២ ពណ.ចបព ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជ-កម្ម នៃក្រសួងពាណិជ្ជកម្ម។

THE ARBITRATION COUNCIL

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត ចុះទិដ្ឋាការលេខ ១០៨ ក.ប.វ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

៥- លិខិតរបស់ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត ផ្ញើជូនកម្មករនិយោជិត ស្តីពីផលប៉ះពាល់នៃវីរុស កូវីដ-១៩ មកលើការបញ្ជាទិញ និងការពន្យារពេលទូទាត់ថ្លៃទំនិញរបស់អ្នកបញ្ជាទិញ។

៦- លិខិត ចុះថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០២០ គោរពជូន នាយកក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត ស្តីពី ការសុំជួបពិភាក្សាជាមួយលោកនាយកក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត លើលក្ខខណ្ឌការងារមួយចំនួន។

៧- លិខិតឆ្លើយតប ចុះថ្ងៃទី៣០ ខែមិថុនា ២០២០ របស់កម្មករនិយោជិត នៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត។

៨- លិខិតឆ្លើយតប ចុះថ្ងៃទី០៣ ខែកក្កដា ២០២០ របស់កម្មករនិយោជិត នៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត។

៩- លិខិតឆ្លើយតប ចុះថ្ងៃទី០៣ ខែកក្កដា ២០២០ របស់កម្មករនិយោជិត នៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត។

១០- លិខិតឆ្លើយតប របស់កម្មករនិយោជិតផ្នែកត្រួតពិនិត្យគុណភាព(QC) នៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត។

១១- តារាងបញ្ជីឈ្មោះ ស្នាមមេដៃអ្នកបដិសេធ របស់កម្មករនិយោជិត នៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត។

១២- គំរូកិច្ចសន្យាការងារមានថិរវេលាកំណត់ របស់ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- សារណាសង្ខេប របស់សហជីពកម្មករប្រជាធិបតេយ្យ ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីវិវាទដែលកើតឡើងនៅក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត ចុះថ្ងៃសុក្រ ១៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ត្រង់ទំព័រទី៤។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០។

THE ARBITRATION COUNCIL

៤- លក្ខន្តិកៈនៃសហជីពកម្មករប្រជាធិបតេយ្យ ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត លេខ ១០៨១៨០០២៣ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ។

៥- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពកម្មករប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត លេខ ០០២៣/១៨ ក.ប/កណ ចុះថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨។

៦- លិខិតលេខ ០០២៣/១៨ ក.ប/កណ ចុះថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា កម្មករប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត ជាអង្គការវិជ្ជាជីវៈមួយ បានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត លេខ ៥៩៨/២០ ក.ប/កណ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា) លីមីតធីត លេខ ០០៧/២០ ក.ប/កណ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៣៣៧ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៣៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកតម្បាញអាវរងា និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០០៧៣៤៦ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៧២៥នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា))។*

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៧/២០ ក.ប/កណ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០២០ ដែលមានកម្មករនិយោជិតចំនួន ២នាក់ មានឈ្មោះ ១. លោក នៅ ប៊ុន ធឿន និង ២. លោក ឈុន បូរី អ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) លីមីតធីត ក្នុងការដោះស្រាយវិវាទការងាររួម។
- យោងតាមលិខិតពឹងពាក់ និងផ្ទេរសិទ្ធិ របស់កម្មករនិយោជិត ជូនសហជីពកម្មករប្រជាធិបតេយ្យ ចុះថ្ងៃ ២២ ខែមិថុនា ឆ្នាំ២០២០ មានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតដែលជាដើមបណ្តឹងសរុបចំនួន ១៧៤នាក់។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកជួយសម្រួលដល់អគារនីមួយៗ ឱ្យមានភាពត្រជាក់ដល់បងប្អូនកម្មករឡើងវិញផង**

- ភាគីនិយោជក និងភាគីកម្មករនិយោជិត បានព្រមព្រៀងគ្នា ដូចខាងក្រោម ៖
  - និយោជកឯកភាពបន្ថែមកង្ហារបូមខ្យល់ឱ្យមានភាពត្រជាក់ជាមុន។
  - និយោជកនឹងកែតម្រូវ និងផ្លាស់ប្តូរកន្លែងសម្ងួត ជូនកម្មករនិយោជិតដើម្បីកាត់បន្ថយកម្តៅនៅកន្លែងដែលកម្មករនិយោជិតធ្វើការ។
  - និយោជកនឹងរៀបចំការកែសម្រួលនេះឱ្យបានយ៉ាងយូរត្រឹមខែមករា ឆ្នាំ២០២១។
- ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនពិចារណាលើការទាមទារនៅក្នុងចំណុចវិវាទទី១ នេះទេ។

**ចំណុចវិវាទទី២ និងទី៣ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកកុំរើសអើងសហជីព និងទាមទារឱ្យនិយោជកអនុញ្ញាតឱ្យតំណាងសហជីពចេញចូល ដូចសហជីពដទៃទៀត ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ឱ្យនៅដដែល**

- ភាគីនិយោជក និងភាគីកម្មករនិយោជិត បានព្រមព្រៀងគ្នា ដូចខាងក្រោម ៖
  - ចំពោះការចូលរួមប្រជុំរបស់សហជីពដែលមានលិខិតអញ្ជើញត្រឹមត្រូវពីស្ថាប័នផ្លូវការ ឬអាជ្ញាធរមានសមត្ថកិច្ច ដូចជាលិខិតអញ្ជើញពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬលិខិតអញ្ជើញពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និយោជកឯកភាពរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតឱ្យនៅដដែល។
  - ចំពោះលិខិតអញ្ជើញចូលរួមការប្រជុំ ឬសិក្ខាសាលា ពីតំណាងសហព័ន្ធផ្សេងៗ ទៀត និយោជកនឹងពិនិត្យតាមស្ថានភាពជាក់ស្តែង។
- ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនពិចារណាលើការទាមទារនៅក្នុងចំណុចវិវាទទី២ និងទី ៣ នេះទេ។

**ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកទូទាត់ប្រាក់រង្វាន់ ឬលុយទៀងទាត់ជូនបងប្អូនកម្មករឡើងវិញ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក នៅក្នុងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិត។
- ភាគីទាំងពីរទទួលស្គាល់ថា ៖

- ចាប់ពីពេលបើកដំណើរការក្រុមហ៊ុនមកនិយោជកអនុវត្តការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិតដែលបានបំពេញការងារមិនមានអវត្តមាន។
- នៅក្នុងខែឧសភា ឆ្នាំ២០២០ ភាគីកម្មករនិយោជិតបានបំពេញការងារតាមគោលការណ៍ដែលបានកំណត់ដើម្បីទទួលបានប្រាក់រង្វាន់លើកទឹកចិត្តនេះ ហើយនិយោជកក៏បានចេញលិខិតបើកប្រាក់រង្វាន់លើកទឹកចិត្តជូនកម្មករនិយោជិតរួចហើយផងដែរ។
- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ និយោជកបើកប្រាក់ឈ្នួល ប្រចាំខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិត។ នៅថ្ងៃដដែល និយោជកបានចេញសេចក្តីជូនដំណឹងពន្យារការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក ជូនកម្មករនិយោជិត ចាប់ពីខែឧសភា រហូតដល់ខែកញ្ញា ឆ្នាំ២០២០។ ក្រោយមក និយោជកបានជូនដំណឹងពន្យារការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិកនេះ រហូតដល់ស្ថានភាពជំងឺកូវីដ១៩ បានធូរស្រាល។
- ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិកនេះ គឺមិនមានកំណត់នៅក្នុងបទប្បញ្ញត្តិច្បាប់ស្តីពីការងារ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬកិច្ចព្រមព្រៀងរវាងភាគីទាំងពីរនោះទេ។

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា និយោជកត្រូវទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តនេះជូនកម្មករនិយោជិត ព្រោះនិយោជកមិនបានជូនដំណឹងមុនអំពីការសុំពន្យារពេលបើកប្រាក់រង្វាន់លើកទឹកចិត្តនេះទេ ហើយកម្មករនិយោជិតក៏បានខិតខំប្រឹងប្រែងបំពេញការងារតាមគោលការណ៍ដែលត្រូវទទួលរង្វាន់លើកទឹកចិត្តសម្រាប់ខែឧសភា ឆ្នាំ២០២០ នេះរួចហើយ។
- ភាគីនិយោជករក្សាគោលជំហរមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - និយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក ជូនកម្មករនិយោជិត គឺមានភាពប្រសើរជាងច្បាប់កំណត់ ហើយប្រាក់នេះ គឺសម្រាប់កម្មករនិយោជិតទិញនំចំណីញ៉ាំតិចតួចប៉ុណ្ណោះ។
  - និយោជកបានជួបវិបត្តិសេដ្ឋកិច្ចដោយសារតែជំងឺកូវីដ១៩ ហើយអ្នកបញ្ជាទិញធំៗចំនួនពីរបានបញ្ចប់កិច្ចសន្យាការបញ្ជាទិញដែលគិតជាចំនួនអាវ គឺប្រហែលចំនួន ៥លានអាវ។ ម្យ៉ាងទៀត ចំនួនថ្ងៃដែលអ្នកបញ្ជាទិញត្រូវទូទាត់ប្រាក់ថ្លៃទំនិញបន្ទាប់ពីទទួលបានទំនិញ គឺត្រូវពន្យារពេលពី ៦០ថ្ងៃ ទៅ ១៦០ថ្ងៃ។
  - និយោជកគ្រោងបើកប្រាក់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក សម្រាប់ខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិត ប៉ុន្តែ ប្រាក់ដែលត្រូវផ្ទេរមកពីអ្នកបញ្ជាទិញនៅហុងកុង ត្រូវពន្យារពេល ហេតុនេះ និយោជកមិនអាចបើកប្រាក់រង្វាន់លើកទឹកចិត្ត ក្នុងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតបានទេ ហើយនិយោជកស្នើសុំឱ្យកម្មករនិយោជិតយោគយល់ពីបញ្ហារបស់និយោជកផងដែរ។
- នៅក្នុងសវនាការ ភាគីនិយោជកបានបញ្ជាក់ថា មានកម្មករនិយោជិតចំនួន ៦០០នាក់ បានផ្តិតមេដៃបដិសេធការទាមទារនេះវិញ ដោយសារពួកគាត់យល់ពីស្ថានភាពលំបាករបស់ក្រុមហ៊ុន។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ៖
  - ភាគីកម្មករនិយោជិតទទួលស្គាល់ថា កម្មករនិយោជិតបានផ្តិតមេដៃបដិសេធការទាមទារក្នុងចំណុចវិវាទនេះវិញ ដោយសារកម្មករនិយោជិតភ័យខ្លាចនិយោជក។

THE ARBITRATION COUNCIL

○ កម្មករនិយោជិតដែលទាមទារឱ្យនិយោជកទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន៥ដុល្លារអាមេរិក ក្នុងខែឧសភា ឆ្នាំ២០២០ មានចំនួនប្រហែល ៣០០នាក់ ប៉ុន្តែ ពួកគាត់មិនមានឈ្មោះ និង ស្នាមមេដៃនៅក្នុងលិខិតពឹងពាក់ និងផ្ទេរសិទ្ធិជូនអ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនោះទេ។

- យោងតាមឯកសាររបស់ភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញ លិខិតឆ្លើយតប ចុះថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ បានបញ្ជាក់ថា៖ *"...យើងខ្ញុំទាំងអស់គ្នាដែលជាកម្មករ ផ្នែកឆែកប៉ះ, ផ្នែកវេចខ្ចប់ និងផ្នែក QC ក៏នឹងយល់ព្រមនៅការស្នើសុំពីសំណាក់ក្រុមហ៊ុន ក្នុងការផ្អាកបណ្តោះអាសន្ន នូវការផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ៥$ ក្នុង ១ខែ រហូតដល់មេរោគរាតត្បាតកូវីត ១៩ ត្រូវបានបញ្ចប់។..."*។ នៅក្នុងលិខិតឆ្លើយតបនេះ មានលេខកាត និងស្នាមមេដៃកម្មករនិយោជិត បញ្ជាក់ការយល់ព្រមសរុបចំនួន ១៧៤នាក់។ ភ្ជាប់ជាមួយលិខិតឆ្លើយតបនេះដែរ មានលេខកាត, ឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតផ្នែកម៉ុកព្រុយ, ផុងថាស, ស្វ័យប្រវត្តិ, ដេរផ្លាកក, ឆែកផ្ទាំង, អ៊ុត, អនាម័យ, ចែកអីវ៉ាន, ឃ្លាំង, រូសអំបោះ, បោកគក់, គំរូ, ដែលបានបដិសេធការទាមទារសរុបចំនួន ៤៦៧នាក់។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងលិខិតឆ្លើយតបខាងលើនោះទេ។

## ហេតុផលនៃសេចក្តីសម្រេច ÷

### ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ ដុល្លារ អាមេរិក នៅក្នុងខែឧសភា ឆ្នាំ២០០២ ជូនកម្មករនិយោជិត

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតលើកឡើងថា ការទាមទារនេះ គឺសម្រាប់កម្មករនិយោជិតចំនួនប្រហែល ៣០០នាក់ ប៉ុន្តែ ភាគីកម្មករនិយោជិតទទួលស្គាល់ថា កម្មករនិយោជិតចំនួនប្រហែល ៣០០នាក់នោះ គឺមិនមានឈ្មោះ និងស្នាមមេដៃនៅក្នុងលិខិតពឹងពាក់ និងលិខិតផ្ទេរសិទ្ធិជូនអ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួមនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

ប្រការ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬអ្នកតំណាង ដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

យោងតាមប្រការ១៩ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួន ក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះ ទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦១/០៩-សិប្បកម្ម ព្រែកត្រែង, លេខ ៤៣/១០-ម៉ឺង ជៀន, លេខ ១៤៤/១២-អ៊ី ហ្គាមេន និងលេខ ១២០/១៥ - ក័ហ្វិក គ្រោស៍ ប្រាយវេត ខូអិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៨១/១៤-ស៊្យុង យិន (ខេមបូឌា) ប៊ី ចិកស្ថាយ៍ ហេតុផលនៃចំណុចវិវាទទី១ បានបកស្រាយថា ៖ *"...ដោយហេតុថា គ្មានភាគីវិវាទ ឬដើមបណ្តឹងជាក់លាក់ និង និងគ្មានភស្តុតាងដើម្បីគាំទ្រអំណះអំណាង.... ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចសម្រេចទៅលើអង្គសេចក្តីនៃចំណុចវិវាទនេះបានទេ។ សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទារ របស់*

THE ARBITRATION COUNCIL

*ភាគីកម្មករនិយោជិត...។" (សូមមើលបន្ថែមសេចក្ដីបង្គាប់អាជ្ញាកណ្ដាល លេខ ២៣០/១៦-រ៉ា ឡុង (ខេមបូឌា) អៅសូល អ៊ិនដាសស្ទ្រី ហេតុផលនៃចំណុចវិវាទទី៥ និងលេខ ០២៦/១៩-ណា ជុង ហ្គាម៉ិន ឯ.ក ហេតុផលនៃចំណុចវិវាទទី១៤ និងលេខ ០៣៤/២០- វ៉ាយវីគី ត្រេឌីង ហេតុផលនៃចំណុចវិវាទទី៨)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាកេឃើញថា ភាគីកម្មករនិយោជិតចំនួន ៣០០នាក់ គឺមិនបានផ្ទេរសិទ្ធិជូនអ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនេះទេ។ ហេតុនេះ យោងតាមអង្គហេតុ និងប្រការ១៩ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ចំណុចវិវាទនេះ គឺមិនមានដើមបណ្ដឹងជាក់លាក់ដែលទាមទារឱ្យនិយោជកផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ ដុល្លារអាមេរិក ក្នុងខែឧសភា ឆ្នាំ២០២០ នោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក ក្នុងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិត។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ៤ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥ដុល្លារអាមេរិក ក្នុងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិត។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **ហែម ហួណារិទ្ធ**

ហត្ថលេខា ៖ ------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **រួន សារ៉ាយ**

ហត្ថលេខា ៖ ------------------------

THE ARBITRATION COUNCIL